**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស និង ខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Oct-2016, 14:54
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹង សំណើរបស់ នួន ជា ទាក់ទិននឹងចំនួនទំព័រ ពេលវេលាកំណត់ និង ខ្លឹមសារសម្រាប់សេចក្តីសន្និដ្ឋានបិទក្នុងសំណុំរឿង ០០២/០២**

---

**<u>ដាក់ដោយ៖</u>**

**<u>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ជេត វណ្ណលី

ហុង គីមសួន

**<u>នៅចំពោះមុខ៖</u>**

**<u>អង្គជំនុំជម្រះសាលាដំបូង៖</u>**

**ចៅក្រម និល ណុន ប្រធាន**

**ចៅក្រម យ៉ា សុខន**

**ចៅក្រម Jean-Marc LAVERGNE**

**ចៅក្រម យូរ ឧត្តរា**

**ចៅក្រម Claudia FENZ**

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

វ៉ែន ពៅ

ទី ស្រីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

**មេធាវីប្រចាំការ៖**

ទូច វរល័ក្ស

Calvin SAUNDERS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE
Patrick BAUDOUIN
Beini YE

## I. សេចក្តីផ្តើម

1. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមឆ្លើយតបទៅនឹងសំណើរបស់ នួន ជា ទាក់ទិននឹងចំនួនទំព័រ ពេលវេលាកំណត់ និង ខ្លឹមសារសម្រាប់សេចក្តីសន្និដ្ឋានបិទក្នុងសំណុំរឿង ០០២/០២[1]។

2. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនជំទាស់ទៅនឹងសំណើទាក់ទិននឹងចំនួនទំព័រ និងពេលវេលាកំណត់ ដែលមេធាវីការពារក្តី នួន ជា បានស្នើសុំនោះទេ។ ទោះជាយ៉ាងណាក្តី សហមេធាវីនាំមុខសូមស្នើដោយទទូចថា ប្រសិនបើមានការបន្ថែមចំនួនទំព័រ និងពន្យារពេលវេលាកំណត់សមស្របណាមួយ ការបន្ថែមនោះក៏គួរតែផ្តល់ដល់ភាគីទាំងអស់ដែរ ដោយសារថា ការពិចារណា និងផលប្រយោជន៍មួយចំនួន ដែលមេធាវីការពារក្តីបានលើកឡើង មានភាពដូចគ្នា ជាពិសេស ទាក់ទិននឹងភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ ទីតាំងឧក្រិដ្ឋកម្ម និងបទឧក្រិដ្ឋជាច្រើនដែលបានចោទប្រកាន់ ភាពស្មុគស្មាញនៃបញ្ហាអង្គច្បាប់ និងលទ្ធភាពក្នុងការស្នើសុំប្រកបដោយប្រសិទ្ធភាព[2]។ ឧទាហរណ៍ ទាក់ទិននឹងផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥៧ នាក់បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២ ទាក់ទិននឹងសវនាការចំនួនប្រាំវគ្គដំបូង (ទាំងអង្គហេតុ និងផលប៉ះពាល់) ដោយដើមបណ្តឹងរដ្ឋប្បវេណី ៥ នាក់ទៀតត្រូវបានជ្រើសរើសឱ្យមកផ្តល់សក្ខីកម្មទាក់ទិននឹងតួនាទីរបស់ជនជាប់ចោទ។ ករណីនេះខុសពីសំណុំរឿង ០០២/០១ ដែលមានដើមបណ្តឹងរដ្ឋប្បវេណីចំនួនតែ ៣១ នាក់ ដែលមកផ្តល់សក្ខីកម្ម។

3. សហមេធាវីនាំមុខក៏មិនជំទាស់ទៅនឹងសំណើទាក់ទិននឹងការរៀបចំកិច្ចប្រជុំរៀបចំសវនាការដែរ។ ទោះជាយ៉ាងណាក្តី សហមេធាវីនាំមុខសូមលើកឡើងថា ជាការប្រសើរជាងប្រសិនបើរៀបចំកិច្ចប្រជុំនេះ បន្ទាប់ពីចេញសាលដីកាលើសំណុំរឿង ០០២/០១ រួច ហើយ បញ្ហាសំខាន់ៗផ្សេង

---

[1] សំណើរបស់ នួន ជា ទាក់ទិននឹងចំនួនទំព័រ ពេលវេលាកំណត់ និង ខ្លឹមសារសម្រាប់សេចក្តីសន្និដ្ឋានបិទក្នុងសំណុំរឿង ០០២/០២ ឯកសារ **E421/5** ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦។

[2] សំណើរបស់ នួន ជា ទាក់ទិននឹងចំនួនទំព័រ ពេលវេលាកំណត់ និង ខ្លឹមសារសម្រាប់សេចក្តីសន្និដ្ឋានបិទក្នុងសំណុំរឿង ០០២/០២ ឯកសារ **E421/5** ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ កថាខណ្ឌ ១៧, ២៧-៣០។

១ទៀតពាក់ព័ន្ធនឹងការរៀបចំសវនាការ គួរតែត្រូវបានដោះស្រាយនាពេលជាមួយគ្នានោះដែរ[3]។ ទាក់ទិននឹងការដាក់សារណាស្តីពីច្បាប់ជាធរមាន សហមេធាវីនាំមុខគាំទ្រដល់ការចង្អុលបង្ហាញពីអង្គជំនុំជម្រះសាលាដំបូងនៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះ ដែលមានចំណងជើងថា *ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២/០២ - ការជូនដំណឹងអំពីកាលបរិច្ឆេទផ្សេងៗ*[4]។

4. សហមេធាវីនាំមុខកត់សម្គាល់ថា សំអាងហេតុ និងផលប្រយោជន៍ស្រដៀងគ្នានេះក៏មានចំពោះបណ្តឹងទាមទារសំណងចុងក្រោយដែរ។ ឧក្រិដ្ឋកម្ម និងព្យសនកម្មជាច្រើននៅក្នុងសំណុំរឿង ០០២/០២ បានផ្តល់យុត្តិកម្មឱ្យមានការស្តាប់សក្ខីកម្មទៅលើផលប៉ះពាល់ចំនួនប្រាំផ្សេងៗគ្នា ដែលកន្លងមក មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៤ នាក់ បានមកផ្តល់សក្ខីកម្ម អំពីព្យសនកម្មដែលពួកគាត់បានទទួលរង ដោយសារឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីនាក់បន្ថែមទៀតកំពុងរង់ចាំការសម្រេច ទាក់ទិននឹងសវនាការលើវគ្គទី៥។ ប្រភេទខុសៗគ្នានៃឧក្រិដ្ឋកម្មតម្រូវឱ្យមានការស្នើបង្កើតគម្រោងសំណងដែលមានសណ្ឋានខុសៗគ្នាផងដែរ ដើម្បីផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលរងព្យសនកម្មពីឧក្រិដ្ឋកម្មជាច្រើនសណ្ឋាននោះ។ ហេតុនេះ សហមេធាវីនាំមុខសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាពិចារណាទៅលើកត្តាទាំងនេះផងដែរនៅការកំណត់ពេលវេលា និងចំនួនទំព័រ ទាក់ទិននឹងបណ្តឹងទាមទារសំណងចុងក្រោយ។

5. ហេតុនេះ សហមេធាវីនាំមុខស្នើសុំឱ្យអង្គជំនុំជម្រះមេត្តាពិចារណាទៅលើផលប្រយោជន៍របស់ភាគីទាំងអស់ នៅពេលសម្រេចអនុញ្ញាតឱ្យបន្ថែមចំនួនទំព័រ និងពន្យារពេលវេលាកំណត់ ព្រោះថាត្រូវមានការរៀបចំបន្ថែមទៀតទាក់ទិននឹងសេចក្តីសន្និដ្ឋានចុងក្រោយនៅក្នុងសំណុំរឿង ០០២/០២។

---

[3] *សូមមើល ឧទាហរណ៍* សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំសេចក្តីបញ្ជាក់ទាក់ទងនឹងបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ឯកសារ **E439** ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៦។

[4] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២/០២ - ការជូនដំណឹងអំពីកាលបរិច្ឆេទផ្សេងៗ ឯកសារ **E421** ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥ ("[អង្គ]ជំនុំជម្រះជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះនឹងស្នើសុំឱ្យដាក់សារណាជាមុនដែលលើកឡើងអំពីច្បាប់ជាធរមាន ក្នុងគោលបំណងមួយចំនួន រួមទាំង (១) ដើម្បីបន្ថែមទៅលើសេចក្តីសន្និដ្ឋានពីមុនៗ ផ្អែកលើការវិវត្តថ្មីៗផ្នែកច្បាប់ និង (២) ដើម្បីធ្វើសេចក្តីសន្និដ្ឋានអំពីឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវដែលមិនមែនជាផ្នែកនៃសំណុំរឿង ០០២/០១។ ការដាក់សារណានឹងត្រូវកំណត់កាលបរិច្ឆេទបន្ទាប់ពីមានការចេញសាលដីកាលើសំណុំរឿង ០០២/០១")។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលយកចម្លើយតបនេះដោយក្ដីគោរព។

| កាលបរិច្ឆេទ | នាម និងគោត្តនាម | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | |